# ជម្ងឺរពិសហួសប្រមាណ

Autism Spectrum Disorders
WUML
10/28/07

ជម្ងឺ Autism (ជួនកាលខ្មែរយើងហៅថា ជម្ងឺរពិសហួសប្រមាណ) ឬភាសាអង់គ្លេសហៅម្យ៉ាងទៀតថា Autism Spectrum Disorder ជាក្រុមជម្ងឺកើតមិនគ្រប់លក្ខណម្យ៉ាង ដែលអាចបណ្តាលឲ្យក្មេង ឬអ្នកជម្ងឺពុំអាចមានលទ្ធភាពនឹងធ្វើការប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ បានធម្មតា ហើយអាចបណ្តាលឲ្យក្មេងបញ្ចេញនូវអកប្បកិរិយានិងចិត្តខុសប្លែកពីអ្នកដទៃ។ មនុស្សយើង ភាគច្រើន ដែលមានលក្ខណប្រភេទនេះ ច្រើនមានបញ្ហាក្នុងការរៀនសូត្រ, ការផ្ចង់អារម្មណ៍ទៅលើអ្វីមួយ, និងការមានប្រតិកម្មទៅលើអ្វីមួយចំឡែកខុសគេ។ ជួនកាល ក្មេងដែលមានបញ្ហានេះ អាចទៅជាឆ្លាតមែនទែន ឬក៏ទៅជាពិបាកគិតគូរធ្វើអ្វីទាំងអស់។

ជម្ងឺ Autism ឬ ជម្ងឺរពិសហួសប្រមាណ អាចមាននៅចំពោះមនុស្សយើងគ្រប់សញ្ជាតិ, គ្រប់សាសន៍, ពុំថាជាអ្នកក្រ ឬអ្នកមានឡើយ ហើយម្យ៉ាងទៀត វាច្រើនមានចំពោះក្មេងប្រុសៗ ជាងក្មេងស្រីៗ។  មជ្ឍមណ្ឌលការពារនិងបង្ក្រាបជម្ងឺ, ប្រព័ន្ធផ្នែកខាងតាមដានជម្ងឺ Autism, Center for Disease Control and Prevention’s Autism and Developmental Disabilities Monitoring Network បានផ្សាយស្ថិតិក្នុងឆ្នាំ 2007 នេះថា មានក្មេងយ៉ាងហោចណាស់ មានក្មេងចំនួន មួយនាក់ ក្នុងចំណោមក្មេង 150 នាក់ ដែលមានអាយុ 8 ឆ្នាំមានជម្ងឺ Autism ក្នុងសហរដ្ឋ។

ក្មេងច្រើនចាប់ផ្តើមមានជម្ងឺ Autism នៅពេលដែលមានអាយុបាន 18 ខែ។  ជាមួយគ្នានឹងពេលដែលមាតាបិតា សង្កេតមើលការលូតលាស់របស់កូន មាតាបិតាក៏គួរឧស្សាហ៍សង្កេតមើល ជាពិសេស ចំពោះកូនដែលមានបញ្ហាសុខភាព ដូចជាក្មេងដែលកើតពីឱពុកម្តាយ ឬបងប្អូន ដែលជម្ងឺនេះ ផងដែរ។ មាតាបិតា គួរឧស្សាហ៍សង្កេតមើល ក្មេងដែលពុំសូវមានសុខភាពល្អ ឲ្យបានជិតដល់ ហើយឧស្សាហ៍យកគ្នាទៅឲ្យគ្រូពេទ្យពិនិត្យឲ្យបានច្បាស់លាស់។

តាមការស្រាវជ្រាវមួយបានឲ្យដឹងថា កម្មវិធីសំរាប់ជួយកុមារពេលគ្នានៅពីតូច ហៅថា Early Childhood Intervention, អាចជួយឲ្យក្មេងមានលទ្ធភាពនឹងលូតលាស់បានយ៉ាងប្រសើរ។ មជ្ឍមណ្ឌល CDC បានធ្វើការ យ៉ាងជិតស្និទជាមួយអង្គការណ៍នានា ក្នុងសហរដ្ឋ ដើម្បីផ្តល់ដំណឹងដល់សាធារណៈជន ឲ្យបានជ្រាបច្បាស់ អំពីវិធីចេះសង្កេតមើលកូននូវសញ្ញាផ្សេងៗ ដែលអាចមានជម្ងឺ Autism នេះ ឲ្យបានកាលនៅតូច។

ជម្ងឺ Autism នេះ បានត្រូវគេរកឃើញកាលពីឆ្នាំ 1943 ដោយវេជ្ជបណ្ឌិតផ្នែកវិកលចរិក (psychiatrist) ឈ្មោះ Dr. Leo Kanner។

គេបានដឹងច្រើនអំពីសញ្ញារោគរបស់ជម្ងឺ Autism និងវិធីផ្សេងៗ ដែលអាចសង្កេត តាមដាន ពិនិត្យមើលជម្ងឺនេះ។ ប៉ុន្តែ គេនៅពុំទាន់ដឹងឲ្យបានច្បាស់លាស់ អំពីមូលហេតុដែលអាចនាំឲ្យកើតជម្ងឺនេះ នៅឡើយទេ។ អ្នកវិទ្យាសាស្ត្រមានជំនឿថា ជម្ងឺនេះនេះគឺប្រហែលជាអាចបណ្តាលមកពីពូជ និងកត្តាផ្សេងៗទៀត ជាច្រើន នៅជុំវិញបរិវេណដែលក្មេងនោះរស់នៅ ហើយ មើលទៅ។

អ្នកដែលមានជម្ងឺ Autism អាចមានបញ្ហាច្រើនក្នុងសង្គម, បញ្ហាផ្លូវចិត្ត, និងបញ្ហាប្រស្រ័យទាក់ទងគ្នាទៅវិញទៅមក ជាមួយអ្នកដទៃ។ ក្មេងមានជម្ងឺនេះ អាចធ្វើអ្វីដដែល ជាដដែល ហើយពិបាកប្តូរពីរបៀបធ្វើអ្វីមួយ ទៅរបៀបធ្វើអ្វីមួយទៀត។ អ្នកដែលកើតជម្ងឺនេះ អាចមានការពិបាកក្នុងការរៀនសូត្រ, ការផ្ចង់អារម្មណ៍ទៅលើអ្វីមួយ, ឬការមានប្រតិកម្មទៅលើអ្វីមួយ។ ជាការមួយ សំខាន់ ដែលគួរជ្រាបថា មនុស្សយើងដែលពុំមានជម្ងឺនេះខ្លះ ក៏អាចមានសញ្ញាទាំងនេះបានដែរ។

ហើយម្យ៉ាងទៀត សូមមេត្តាជ្រាបថា ក្មេងដែលកើតជម្ងឺ Autism ក៏អាចធ្លាក់ខ្លួនឈឺ, មានគ្រោះថ្នាក់របួស ដូចជាក្មេងដទៃទៀតបានដែរ។  ដូច្នេះហើយ បានជាការចាំបាច់ គួរឧស្សាហ៍យកកូនទៅពិនិត្យសុខភាព, ពិនិត្យធ្មេញ ដើម្បីការពារកុំឲ្យគ្នាធ្លាក់ខ្លួនឈឺទាន់។ វាជាការមួយដែលពិបាកឲ្យយើងដឹងណាស់ថា តើចរិកដែលក្មេងបញ្ចេញឲ្យឃើញនោះ ជាសញ្ញារបស់ជម្ងឺ Autism ឬជាអាការៈរោគរបស់ជម្ងឺដទៃទៀត នោះណាស់។ ឧទាហរណ៍ ដូចជា នៅពេលក្មេងចេះតែបោកក្បាលខ្លួនឯងទៅនឹងជញ្ជាំង។ នេះអាចជាសញ្ញារបស់ជម្ងឺ Autism ឬក៏ជាអាការៈដែលឲ្យយើងដឹងថា ក្មេងប្រហែលជាឈឺក្បាល។ ក្នុងលក្ខណនេះ ការយកក្មេងទៅពិនិត្យសុខភាព ជាការមួយសំខាន់ណាស់។

លំដាប់តទៅនេះ ជាសញ្ញាខ្លះៗដែលក្មេងឬមនុស្សពេញវ័យ មានជម្ងឺ Autism អាចបញ្ចេញឲ្យយើងដឹងបាន, សញ្ញាទាំងនេះ មានដូចជា៖

- ក្មេងមិនអាចចង្អុលប្រាប់ ទៅរបស់អ្វីមួយដែលខ្លួនចង់បាន តែ
- ពិបាកនិយាយប្រាប់គេឲ្យដឹង ប្រសិនបើខ្លួនចង់បានអ្វីមួយ
- មិនប្រឡេកមើលទៅរបស់អ្វីមួយ ដែលមានគេចង្អុលប្រាប់
- ដូចជាមិនចេះយកចិត្តទុកដាក់ លេងជាមួយក្មេងឬអ្នកដទៃ

- ជៀសវាងមិនក្រឡេកមើលចំមុខមនុស្ស ឬចង់តែនៅលេងម្នាក់ឯង
- មិនសូវយល់ចិត្ត ឬយល់ទុក្ខធុរៈរបស់អ្នកដទៃ
- មិនចង់ឲ្យមានគេបី ឬពរថ្នាក់ថ្នម រហូតទាល់តែពេលណា ចង់ខ្លួនឯង
- គ្មានបញ្ចេញប្រតិកម្មអ្វីសោះ នៅពេលណាដែលមានគេនិយាយរក តែអាចមានប្រតិកម្មទៅ លើសម្លេងអ្វីមួយ ទៅវិញ
- ជួនកាល ក្មេងចូលចិត្តនណារម្នាក់ ប៉ុន្តែពុំដឹងថា តើត្រូវនិយាយប្រស្រ័យទាក់ទង ឬលេងជាមួយ ដោយរបៀបណា
- ជួនកាល ក្មេងនោះនិយាយត្រាប់តាមមនុស្សដែលនិយាយរក ដោយសម្លេងធម្មតា
- ចូលចិត្តធ្វើអ្វីមួយ ដដែល ដដែល ឬ
- ពិបាកផ្លាស់ប្តូរទៅធ្វើអ្វីមួយ ដែលខ្លួនពុំធ្លាប់ធ្វើពីមុន ម្យ៉ាងទៀត ក្មេងអាច
- មានប្រតិកម្មចំណែកខុសគេឯង នៅពេលណាដែលមានធុំក្លិន, ភ្លក់រសជាតិ, ឬឮសម្លេងអ្វីមួយ។

ប្រសិនបើលោកអ្នក ឬគ្រូពេទ្យលោកអ្នកយល់ថា កូនប្រហែលជាមានអាការៈទាំងប៉ុន្មាន ដែលខ្ញុំបាទបានអធិប្បាយអំបាញមិញនេះ សូមមេត្តាពិភាក្សាជាមួយគ្រូពេទ្យនោះ ឲ្យបញ្ជូនកូនរបស់លោកអ្នក ទៅគ្រូពេទ្យឯកទេសខាងការលូតលាស់របស់ក្មេង។ ម្យ៉ាងទៀត លោកអ្នកអាចទូរស័ព្ទទៅ កម្មវិធីជួយក្មេងពេលនៅពីតូច ដែលហៅថា Early Childhood Intervention (សំរាប់ក្មេង ដែលមាន អាយុតិចជាង 3 ឆ្នាំ) ឬទៅសាលាសាធារណៈ (សំរាប់ក្មេងលើសពីអាយុ 3 ឆ្នាំ)។

ចំពោះ អស់លោក-លោកស្រីនៅទីក្រុងឡូវែល ដែលមានកូនអាយុតិចជាងអាយុ 3 ឆ្នាំ ហើយសង្ស័យថាមានអាការៈទាំងនេះ អស់លោក-លោកស្រីអាចទូរស័ព្ទកម្មវិធី Early Intervention នៅ មជ្ឈមណ្ឌល Anne Sullivan Center ទូរស័ព្ទ លេខ (978) 453-8331 ឬ South Bay Early Intervention ទូរស័ព្ទលេខ (978) 452-1736។ ក្រៅពីនេះ សូមមេត្តាអានបញ្ជីកម្មវិធីផ្សេងៗ តាមរយៈវ៉ិបសៃរបស់មជ្ឈមណ្ឌលជាតិផ្នែកខាងផ្តល់ពត៌មានសំរាប់ក្មេងពិការ, National Dissemination Center for Children with Disability ដែលមានអាសយដ្ឋាន www.nichcy.org ។

ចំពោះពត៌មានបន្ថែម ស្តីអំពីជម្ងឺ Autism ឬជម្ងឺ រពិសហួសប្រមាណ សូមមេត្តាអាន វ៉ិបសៃរបស់មជ្ឈមណ្ឌលការពារ និងបង្ក្រាបជម្ងឺ, Center for Disease Control and Prevention អាសយដ្ឋាន www.cdc.gov ។

*អត្ថបទនេះដកស្រង់និងបកប្រែចេញពីមជ្ឈមណ្ឌលការពារនិងបង្ការជម្ងឺ, Center for Disease Control and Prevention ដោយមណ្ឌលមេត្តាសុខភាពនៃមណ្ឌលសុខភាពសហគមន៍ក្រុងឡូវែល។*